*For Immediate Release*
*19 December 2013*

## ILO Better Factories Cambodia Programme gets new three-year MOU

PHNOM PENH, Cambodia – The International Labour Organization (ILO), the Ministry of Commerce, the Ministry of Labour and Vocational Training, and the Garment Manufacturers Association in Cambodia (GMAC) signed a new Memorandum of Understanding yesterday for its Better Factories Cambodia programme that aims to consolidate improvements in working conditions and competitiveness in Cambodia's garment industry.

The new three-year MOU emphasizes improvements in the garment industry, including expanded data-sharing with the Royal Government of Cambodia detailing compliance and non-compliance of individual factories with Cambodia labour law and internationally recognized core labour standards. The agreement also promotes the enforcement role of the Royal Government of Cambodia and acknowledges the re-introduction of public disclosure as mechanisms to help make significant and sustainable improvements across the industry.

The agreement increases financial support from GMAC and the government for the programme that follows economic trends in the Cambodian garment industry.

Excellency Sun Chanthol, Senior Minister, Minister of Commerce said: "The signing of the MOU today reflects the commitment of the Royal Government of Cambodia to work closely with the ILO and GMAC to ensure that Cambodian labour law and internationally recognized core labour standards are properly implemented. We want Cambodia to be the strongest and most socially compliant garment industry in the region and in the world. We want the "Made in Cambodia brand" to be associated with quality products made by workers that have their working conditions and rights respected."

Excellency Ith Sam Heng, Minister of Labour and Vocational Training noted that "The Royal Government of Cambodia has been and will continue to commit to make sure that workers' right and labour standards are enforced in order to build a good image of products made in Cambodia to compete effectively in the world market. We urge the international buyers to increase their orders from Cambodia."

Mr. Van Sou Ieng, President of the Garment Manufacturers Association in Cambodia (GMAC) said today that "GMAC fully supports the policy of the Cambodian Government to link trade and labor compliance and calls on all buyers to also commit to this in practical terms through an increase in sourcing price and quantity."

Maurizio Bussi, Officer in Charge of ILO Country Office for Cambodia noted that the MOU is the result of extensive consultations with the Ministries of Labour and Vocational Training, Commerce and the ILO's national tripartite partners. "The ILO looks forward to working constructively with Cambodian constituents and international partners over the life of the MOU in an area of central importance to Cambodia as part of the agreed commitment to advance with the effective implementation of the Decent Work agenda. Sustained coordination and a solid alignment of all our collaborative efforts will continue to be central to our work."

The MOU has been renewed four times by the parties since the ILO programme began in 2001.

*Better Factories Cambodia is a programme created to help building the economy and competitiveness of Cambodia through performing assessments on the working conditions in the garment factories based on Cambodia Labour Law and internationally recognized core labour standards and its reporting.*

For more information please contact:

Mr. Jason Judd
Technical Specialist at ILO-Better Factories Cambodia
Tel: 023 212 847
Email: judd@ilo.org

Mr. Ken Loo
Secretary General
Tel: 023 301 181
Email: kenloo@gmac-cambodia.org

Mr. Ken Ratha
Spokeman for Ministry of Commerce
Tel: 070 545 527
Email: kenratha_ait@yahoo.com

His Excellency Heng Sour
Spokeman for Ministry of Labour and Vocational Training
Tel: 012 693 777
Email: hengsour@yahoo.com

International Labour Organization

GMAC

Garment Manufacturers Association in Cambodia

*សម្រាប់ការចេញផ្សាយជាបន្ទាន់*
*ថ្ងៃព្រហស្បត្តិ៍ទី១៩ខែធ្នូឆ្នាំ២០១៣*

## គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជារបស់ (ILO) ទទួលបានអនុស្សរណៈនៃការយោគយល់ថ្មី ដែលមានរយៈពេលបីឆ្នាំ

ភ្នំពេញ ប្រទេសកម្ពុជា– អង្គការអន្តរជាតិខាងការងារ (ILO) និងក្រសួងពាណិជ្ជកម្ម និង ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ព្រមទាំង សមាគមរោងចក្រកាត់ដេរនៅកម្ពុជា(GMAC) បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ថ្មីកាលពីម្សិលមិញ សម្រាប់បន្តគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា ក្នុងគោលបំណងរួមគ្នាពង្រឹងការកែលម្អរលក្ខខណ្ឌការងារ និងភាពប្រកួតប្រជែងនៃឧស្សាហកម្មកាត់ដេររបស់ប្រទេសកម្ពុជា។

អនុស្សរណៈនៃការយោគយល់ថ្មីដែលមានរយៈពេលបីឆ្នាំនេះ បានគូសបញ្ជាក់យ៉ាងច្បាស់នូវចំណុចដែលត្រូវធ្វើឱ្យប្រសើរឡើងនៅក្នុងឧស្សាហកម្មកាត់ដេរ ក្នុងនោះរួមមានការពង្រីកការចែករំលែកព័ត៌មានជាមួយរាជរដ្ឋាភិបាលកម្ពុជានូវពត៌មានលំអិតស្តីពីការអនុវត្ត ឬមិនបានអនុវត្តតាមច្បាប់ស្តីពីការងារនៃព្រះរាជាណាចក្រកម្ពុជា និងបទដ្ឋានការងារស្នូលដែលទទួលស្គាល់ជាអន្តរជាតិរបស់រោងចក្រកាត់ដេរនីមួយៗ។ កិច្ចព្រមព្រៀងនេះក៏លើកកម្ពស់តួនាទីរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអនុវត្តច្បាប់ និងទទួលស្គាល់ការអនុវត្តឡើងវិញនូវការផ្សព្វផ្សាយជាសាធារណៈ ដែលជាយន្តការមួយជួយធ្វើឱ្យមានការកែលម្អនូវចំណុចជាច្រើនដែលមានលក្ខណៈសំខាន់ និងធានានូវនិរន្តរភាពសម្រាប់ឧស្សាហកម្មនេះទាំងមូល។

អនុស្សារណៈនៃការយោគយល់នេះនឹងបង្កើនតួលេខគាំទ្រផ្នែកហិរញ្ញវត្ថុពីសមាគមរោងចក្រកាត់ដេរនៅកម្ពុជា និងរាជរដ្ឋាភិបាលកម្ពុជា ហើយតួលេខនៃការគាំទ្រនេះគឺអាស្រ័យទៅលើនិន្នាការសេដ្ឋកិច្ចនៃទំហំនាំចេញរបស់វិស័យឧស្សាហកម្មកាត់ដេរនៅកម្ពុជា។

ឯកឧត្តមទេសរដ្ឋមន្ត្រី **ស៊ុន ចាន់ថុល** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មបានមានប្រសាសន៍ថា "ការចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់នៅថ្ងៃនេះគឺ ឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការធ្វើការយ៉ាងជិតស្និទ្ធជាមួយអង្គការអន្តរជាតិខាងការងារ និងសមាគមរោងចក្រកាត់ដេរនៅកម្ពុជាដើម្បីធានាឲ្យបានថាច្បាប់ការងារកម្ពុជា និងបទដ្ឋានការងារស្នូលដែលទទួលស្គាល់ជាអន្តរជាតិត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវ។ យើងចង់ឲ្យវិស័យកាត់ដេរកម្ពុជាត្រូវបានដឹងឮជាសាធារណៈថាជាវិស័យមួយដែលគោរពទៅតាមបទដ្ឋានស្តង់ដារច្រើនជាងគេ និងខ្លាំងជាងគេនៅក្នុងតំបន់ និងពិភពលោក។ យើងចង់បាន "ម៉ាកដែលផលិតនៅប្រទេសកម្ពុជា" ត្រូវបានផ្សារភ្ជាប់ជាមួយនឹងផលិតផលដែលមានគុណភាព និងផលិតដោយកម្មករដែលទទួលបានការគោរពសិទ្ធិ និងមានលក្ខខណ្ឌការងារល្អពេញលេញ។

ឯកឧត្តម **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានកត់សម្គាល់ថា "រាជរដ្ឋាភិបាលកម្ពុជាបាននឹងកំពុងបន្តប្តេជ្ញាចិត្តក្នុងការធ្វើឲ្យប្រាកដថាសិទ្ធិ និងបទដ្ឋានការងាររបស់កម្មករត្រូវបានអនុវត្តដើម្បី កសាង

ឲ្យបាននូវកេរ្តិ៍ឈ្មោះល្អនៃផលិតផលដែលផលិតនៅក្នុងប្រទេសកម្ពុជា ដើម្បីប្រកួតប្រជែងឈ្នះគេនៅក្នុងទីផ្សារពិភពលោក។ យើងសូមជំរុញអ្នកទិញអន្តរជាតិឲ្យបង្កើនការបញ្ជាទិញពីកម្ពុជា”។

លោក **វ៉ាន់ ស៊ូអៀង** ប្រធានសមាគមរោងចក្រកាន់ដេរកម្ពុជា បានមានប្រសាសន៍ថា “សមាគមរោងចក្រកាត់ដេរកម្ពុជាគាំទ្រយ៉ាងពេញលេញនូវគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការភ្ជាប់ពាណិជ្ជកម្ម ទៅនឹងការគោរពលក្ខខ័ណ្ឌការងារ ព្រមទាំងអំពាវនាវដល់អ្នកបញ្ជាទិញទាំងអស់សូមរួមចំណែកអនុវត្តនូវលក្ខខណ្ឌ នេះដោយពិតប្រាកដតាមរយៈការបង្កើនថ្លៃ និងបរិមាណបញ្ជាទិញពីកម្ពុជា។

លោក Maurizio Bussi ប្រធានទទួលបន្ទុកការិយាល័យនៃអង្គការអន្តរជាតិខាងការងារប្រចាំ កម្ពុជាបានកត់សម្គាល់ថា អនុស្សរណៈនៃការយោគយល់នេះ គឺជាលទ្ធផលនៃការពិភាក្សាយ៉ាងទូលំទូលាយជាមួយ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងពាណិជ្ជកម្ម ព្រមទាំងដៃគូរត្រីភាគីជាតិរបស់អង្គការអន្តរជាតិ ខាងការងារ (ILO)។ ក្នុងអាណត្តិនៃអនុស្សរណនៃការយោគយល់នេះ អង្គការអន្តរជាតិខាងការងារ (ILO) នឹងរងចាំធ្វើការប្រកបដោយន័យស្ថាបនាជាមួយគ្រប់ស្ថាប័នកម្ពុជា និងដៃគូអន្តរជាតិនានាលើផ្នែកទាំងឡាយណា ដែលមានសារៈសំខាន់សម្រាប់កម្ពុជាដោយអនុលោមទៅតាមការសន្យាកន្លងមករបស់អង្គការអន្តរជាតិខាងការងារ (ILO) ដើម្បីធ្វើឲ្យមានការរីកចំរើន ក្នុងការអនុវត្តប្រកបដោយប្រសិទ្ធិភាពនៃកម្មវិធីការងារសមរម្យ។

អនុស្សរណៈនៃការយោគយល់នេះត្រូវបានបន្តចំនួនបួនលើករួចមកហើយដោយភាគីពាក់ព័ន្ធចាប់តាំងពីកម្មវិធីនេះចាប់ផ្តើមនៅឆ្នាំ២០០១។

គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជាគឺជាកម្មវិធីដែលបង្កើតឡើងដើម្បីជួយកសាងសេដ្ឋកិច្ច និងភាពប្រកួតប្រជែងកម្ពុជាតាមរយៈធ្វើការវាយតម្លៃ និងធ្វើរបាយការណ៍ស្តីពីលក្ខខណ្ឌការងារក្នុងរោងចក្រកាត់ដេរដោយផ្អែកលើច្បាប់ស្តីពីការងារនៃប្រទេសកម្ពុជា និងបទដ្ឋានការងារស្នូលដែលទទួលស្គាល់ជាអន្តរជាតិ។

សម្រាប់ពត៌មានបន្ថែមសូមទំនាក់ទំនងមកកាន់៖

Mr. Jason Judd
Technical Specialist at ILO-Better Factories Cambodia
Tel: 023 212 847
Email: judd@ilo.org

Mr. Ken Loo
Secretary General
Tel: 023 301 181
Email: kenloo@gmac-cambodia.org

Mr. Ken Ratha
Spokeman for Ministry of Commerce
Tel: 070 545 527
Email: kenratha_ait@yahoo.com

His Excellency Heng Sour
Spokeman for Ministry of Labour and Vocational Training
Tel: 012 693 777
Email: hengsour@yahoo.com